ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

EAC

អាជ្ញាធរអគ្គិសនីកម្ពុជា

លេខ០៧៥-សណ១៧អអក

ភ្នំពេញ, ថ្ងៃទី០១ ខែមីនា ឆ្នាំ២០១៧

# សេចក្តីជូនដំណឹងរបស់អាជ្ញាធរអគ្គិសនីកម្ពុជា
## ស្តីពីការពិគ្រោះយោបល់សាធារណៈក្នុងការកែសម្រួលអាជ្ញាបណ្ណរបស់ លោក កែ សារឿន សម្រាប់ធ្វើសេវាកម្មអគ្គិសនីនៅផ្នែកខ្លះនៃស្រុកជលគិរី ខេត្តកំពង់ឆ្នាំង

អាជ្ញាធរអគ្គិសនីកម្ពុជាមានកិត្តិយសសូមជម្រាបជូនសាធារណជននៅក្នុងស្រុកជលគិរី ខេត្តកំពង់ឆ្នាំង ឲ្យបានជ្រាបថា អាជ្ញាធរអគ្គិសនីកម្ពុជាបានចេញអាជ្ញាបណ្ណលេខ ២៩៨ អ ចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ២០១០ ឲ្យលោក កែ សារឿន សម្រាប់ធ្វើសេវាកម្មអគ្គិសនីនៅផ្នែកខ្លះនៃស្រុកជលគិរី ខេត្តកំពង់ឆ្នាំង ក្នុងអាណត្តិមុនគឺ ០៥ ឆ្នាំ ។ ដើម្បីជួយសម្រួលអ្នកកាន់អាជ្ញាបណ្ណក្នុងការខ្ចីទុនពីមូលនិធិអគ្គិសនីភាវូបនីយកម្មជនបទ និងពីប្រភពហិរញ្ញវត្ថុនានា សម្រាប់ការពង្រីកការផ្គត់ផ្គង់អគ្គិសនីទៅកាន់តំបន់ដែលពុំមានអគ្គិសនីប្រើប្រាស់នៅក្នុងតំបន់អាជ្ញាបណ្ណរបស់ខ្លួន និងយោងតាមការវាយតម្លៃលើការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធកន្លងមក អាជ្ញាធរអគ្គិសនីកម្ពុជាគ្រោងចេញសេចក្តីសម្រេចកែសម្រួលអាជ្ញាបណ្ណឲ្យលោក កែ សារឿន ដោយបន្ថែមអាណត្តិអាជ្ញាបណ្ណពី ០៥(ប្រាំ)ឆ្នាំ ទៅ ១២(ដប់ពីរ)ឆ្នាំ ដូចមានខ្លឹមសារជូនភ្ជាប់ ។ យោងតាមនីតិវិធីរបស់អាជ្ញាធរអគ្គិសនីកម្ពុជាក្នុងការកែសម្រួលអាជ្ញាបណ្ណ អាជ្ញាធរមូលដ្ឋាន ស្ថាប័នរដ្ឋនានាដែលពាក់ព័ន្ធ និងសាធារណជនមានសិទ្ធិពិនិត្យផ្តល់យោបល់ និងអនុសាសន៍ឲ្យអាជ្ញាធរអគ្គិសនីកម្ពុជាលើខ្លឹមសារនៃសេចក្តីព្រាងសេចក្តីសម្រេចកែសម្រួលអាជ្ញាបណ្ណដែលគ្រោងនឹងចេញនេះ ។

អាជ្ញាធរអគ្គិសនីកម្ពុជានឹងតម្កល់ទុកសេចក្តីព្រាងសេចក្តីសម្រេចកែសម្រួលអាជ្ញាបណ្ណនៅ.......................................................................................................................................សម្រាប់សាធារណជនពិនិត្យ ។

អាស្រ័យហេតុនេះ សូមសាធារណជននៅក្នុងស្រុកជលគិរី ខេត្តកំពង់ឆ្នាំង ដែលមានចំណាប់អារម្មណ៍ចង់ពិនិត្យ ឬផ្តល់យោបល់លើខ្លឹមសារនៃការចេញសេចក្តីសម្រេចកែសម្រួលអាជ្ញាបណ្ណឲ្យលោក កែ សារឿន អាចអញ្ជើញមកទីកន្លែងខាងលើដើម្បីពិនិត្យឯកសារពាក់ព័ន្ធ និងផ្តល់មតិឲ្យអាជ្ញាធរអគ្គិសនីកម្ពុជាចាប់ពីថ្ងៃប្រកាសជូនដំណឹងនេះ រហូតដល់ថ្ងៃទី២០ ខែមេសា ឆ្នាំ២០១៧ ។ អាជ្ញាធរអគ្គិសនីកម្ពុជាសូមបញ្ជាក់ជូនថា " **អាជ្ញាធរអគ្គិសនីកម្ពុជានឹងធ្វើការពិចារណាតែចំពោះមតិយោបល់ណា ដែលមានបង្ហាញនូវហេតុផលយ៉ាងច្បាស់លាស់ប៉ុណ្ណោះ** " ។

**អាជ្ញាធរអគ្គិសនីកម្ពុជា**

**ប្រធាន**

បណ្ឌិត.ឌិត និរិទ្ធ

**អាជ្ញាធរអគ្គិសនីកម្ពុជា** : ផ្ទះលេខ ០២ ផ្លូវលេខ ២៨២ (ផ្លូវបត់ស្តាំទី ១ ខាងត្បូងវិមានឯករាជ្យ) សង្កាត់បឹងកេងកង ១ ខណ្ឌចំការមន រាជធានីភ្នំពេញ,
ទូរស័ព្ទ : ០២៣ ២១៧ ៦៥៤ / ៩៨៧ ៨៩៨ ទូរសារ : ០២៣ ២១៤ ១៤៤, អ៊ីម៉ែល : admin@eac.gov.kh ; Website : www.eac.gov.kh

**សេចក្ដីព្រាង**

# អាជ្ញាធរអគ្គិសនីកម្ពុជា

**ELECTRICITY AUTHORITY OF CAMBODIA**

## ច្បាប់ស្ដីពីអគ្គិសនីនៃព្រះរាជាណាចក្រកម្ពុជា

**ELECTRICITY LAW OF THE KINGDOM OF CAMBODIA**

## សេចក្ដីសម្រេចកែសម្រួលលើកទី៤
## លើឯកសារអាជ្ញាបណ្ណលេខ ២៩៨ ឯអ ចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ២០១០ សម្រាប់លោក កែ សារឿន ធ្វើសេវាកម្មអគ្គិសនី នៅផ្នែកខ្លះនៃស្រុកជលគិរី ខេត្តកំពង់ឆ្នាំង

## សម្រាប់ការបន្ថែមអាណត្តិអាជ្ញាបណ្ណ

**(ក្នុងគោលបំណងជួយសម្រួលការខ្ចីឥណទានពីមូលនិធិអគ្គិសនីភាវូបនីយកម្មជនបទ "ម.អ.ជ" ដើម្បីពង្រីកបណ្ដាញទៅតំបន់ពុំទាន់មានអគ្គិសនី)**

## DECISION ON THE FOURTH REVISION

OF THE LICENSE DOCUMENT No. 298 LD DATED OCTOBER 27, 2010
FOR MR. KE SAROEUN FOR PROVIDING ELECTRIC POWER SERVICE AT
SOME PART CHULKIRI DISTRICT, KAMPONG CHHNANG PROVINCE

## FOR EXTENDING THE TERM OF LICENSE

**(To facilitate to get the funds from Rural Electrification Fund "REF" for extending the electric supply to non-electrified areas)**

**ថ្ងៃទី ខែ ឆ្នាំ២០១៧**

**….. ….., 2017**